# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៤២ គ.ជ.ប ស.ល.រ

## សេចក្តីណែនាំ
## ស្តីពី
## កិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ នៅថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨

- យោងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ផ្អែកតាមអនុក្រឹត្យលេខ ១២៦.អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩
- ផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០០៩ ផ.ក/១៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩
- យោងប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- យោងសេចក្តីណែនាំរួម លេខ ០០១ គ.ស.អ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីសកម្មភាព និងការរៀបចំសន្តិសុខបោះឆ្នោត ការពារការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ។

ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិយាកាសនយោបាយល្អ ស្ងប់ស្ងាត់ អព្យាក្រឹត និងយុត្តិធម៌ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦

ឆ្នាំ២០១៨ នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមណែនាំដល់លោក លោកស្រី ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ដូចខាងក្រោម ៖

១- បន្តការពង្រឹងទំនាក់ទំនង កិច្ចសហការឱ្យកាន់តែខ្លាំងក្លាថែមទៀតជាមួយនឹងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ពិសេសស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីចាត់វិធានការការពារសន្តិសុខ សុវត្ថិភាពឱ្យបានតឹងរ៉ឹង ផ្អែកតាមគោលការណ៍ដែលបានកំណត់នៅក្នុងផែនការអន្តរស្ថាប័នលេខ ០០៩ ជ.ក/១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ។

២- ត្រូវពង្រឹង កិច្ចសហការចាត់វិធានការ រក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ គ្រប់សកម្មភាពរបស់ភ្នាក់ងារ និងបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងប្រជាពលរដ្ឋដែលអញ្ជើញទៅបោះឆ្នោត ដែលចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ឱ្យបានមធ្យ័តបំផុតតាមសមត្ថកិច្ចដែនដីរបស់ខ្លួន ។

៣- ត្រូវចាត់ចែង តាមដានត្រួតពិនិត្យសភាពការណ៍ និងស្នើសុំអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច ក្នុងករណីមានការអុកឡុក ការគំរាមកំហែង អំពើហិង្សាល្មើសច្បាប់ផ្សេងៗ ដែលនាំឱ្យរាំងស្ទះដល់ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ នេះ ។

៤- ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍ជាប្រចាំ អំពីស្ថានភាពសន្តិសុខ សុវត្ថិភាព ជុំវិញដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ផ្ញើជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប ឱ្យបានទៀងទាត់ ចាប់ពីពេលនេះតទៅ។ ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់ជូនថ្នាក់ដឹកនាំ ដើម្បីមានវិធានការដោះស្រាយឱ្យបានទាន់ពេលវេលា ។

៥- ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលដៅជួបពិភាក្សា និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងការចាត់វិធានការផ្សេងៗ ដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬក៏បាតុភាពនានា ដែលអាចនឹងកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត ។ កិច្ចប្រជុំត្រូវរៀបចំក្នុងមួយសប្តាហ៍ម្តង និងអាចកោះប្រជុំតាមការចាំបាច់ ។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន គធ.ខប ជាសហប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ០១រូប ដែលជាសមាជិកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ជាសហប្រធាន
- តំណាង០១រូបៗ នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរាជធានី ខេត្ត នីមួយៗ ជាសមាជិក
- តំណាង ០១រូបៗ នៃអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ

ក្នុងរាជធានី ខេត្ត ជាសមាជិក

- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស ឬយោធភូមិភាគទី ១-៥ ក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ឬតំណាង ០១ រូប ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក

ទទួលបាននូវសេចក្តីណែនាំនេះ សូម លោក លោកស្រី ប្រធាន គធ.ខប យកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហស្បតិ៍ ១២ រោច ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ស៊ិក ប៊ុនហុក

<u>ចម្លងជូន</u> :

- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គណៈអភិបាល និងជាគណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លេខាធិការដ្ឋានសន្តិសុខបោះឆ្នោត គ.ជ.ប
- ឯកសារ-កាលប្បវត្តិ